ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ....០៥៦..........អ.ស.ហ..ប្រក

# ប្រកាស
## ស្តីពី
## ភាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាត
## របស់ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

#១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
#168F, St. 598, Chrang Chamres 1, Russei Keo, Phnom Penh
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩៩ ៧០០
Phone: (+855) 23 999 700

- បានឃើញប្រកាសលេខ ០០១/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ
- យោងតាមការចាំបាច់របស់និយ័តករមូលបត្រកម្ពុជា

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងកំណត់ពីកាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងបទប្បញ្ញត្តិដទៃទៀតក្នុងវិស័យមូលបត្រ ដើម្បីត្រួតពិនិត្យ និងតាមដាននូវការបំពេញកាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

**ប្រការ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុដែលទទួលបានអាជ្ញាបណ្ណ/ ការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា(**ន.ម.ក.**) និងបុគ្គលពាក់ព័ន្ធក្នុងប្រតិបត្តិការអាជីវកម្មផ្តល់ប្រឹក្សាហិរញ្ញវត្ថុ។

**ប្រការ៣ .-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងមាននៅក្នុងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ។

**បុគ្គលិកជាន់ខ្ពស់** សំដៅដល់បុគ្គលិកបម្រើការងារនៅក្នុងក្រុមហ៊ុនដែលមានតំណែងចាប់ពីប្រធានផ្នែករហូតដល់នាយកប្រតិបត្តិ រួមទាំងអភិបាល។

**បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ** សំដៅដល់អភិបាល ឬសហកម្មសិទ្ធិករ នាយកប្រតិបត្តិ ប្រធានភ្នាក់ងារផ្តល់ប្រឹក្សាហិរញ្ញវត្ថុ និងបុគ្គលិកជំនាញផ្នែកច្បាប់ ដែលទទួលបានការទទួលស្គាល់គុណវុឌ្ឍិពី **ន.ម.ក.**។

**មូលធនភាគហ៊ុនិក (Shareholders' Equity)** សំដៅដល់ទ្រព្យសកម្មដែលនៅសល់ចុងក្រោយ បន្ទាប់ពីបានដកបំណុលទាំងអស់ចេញពីទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

## ជំពូកទី ២
## ភាតព្វកិច្ចផ្តល់របាយការណ៍

**ប្រការ៤ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវផ្តល់ជូន **ន.ម.ក.** ជាប្រចាំខែនូវរបាយការណ៍ស្តីពីស្ថានភាពអាជីវកម្មផ្តល់ប្រឹក្សាហិរញ្ញវត្ថុ។

**ប្រការ៥ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវផ្តល់ជូន **ន.ម.ក.** នូវរបាយការណ៍ប្រចាំឆមាសដូចខាងក្រោម÷

១- របាយការណ៍ហិរញ្ញវត្ថុផ្ទៃក្នុងដែលបានរៀបចំអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងគណនេយ្យ និងសវនកម្ម។

២- របាយការណ៍អំពីការជួញដូរមូលបត្ររបស់ក្រុមហ៊ុន អភិបាល សហកម្មសិទ្ធិករ និងនិយោជិតរបស់ក្រុមហ៊ុន។

៣- របាយការណ៍ស្តីពីការត្រួតពិនិត្យផ្ទៃក្នុង។

៤- របាយការណ៍អំពីភាគហ៊ុនិក ក្រុមប្រឹក្សាភិបាល បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ ភ្នាក់ងារផ្តល់ប្រឹក្សាហិរញ្ញវត្ថុ និងនិយោជិត។

៥- របាយការណ៍ស្តីពីការវាយតម្លៃរបស់បុគ្គលិកជំនាញផ្នែកច្បាប់លើអនុលោមភាពតាមច្បាប់របស់ក្រុមហ៊ុន។

៦- របាយការណ៍ស្តីពីការដោះស្រាយវិវាទ និងពាក្យបណ្តឹង។

**ប្រការ៦ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវផ្តល់ជូន **ន.ម.ក.** នូវរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម÷

១- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវបានធ្វើសវនកម្មរួចដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រដែលទទួលបានការទទួលស្គាល់ពី **ន.ម.ក.**។

២- របាយការណ៍អំពីសមិទ្ធផល និងបញ្ហាប្រឈម ដែលអនុវត្តតាមផែនការអាជីវកម្មដែលបានដាក់តម្កល់នៅ **ន.ម.ក.**។

៣- អង្គការលេខបច្ចុប្បន្នរបស់ក្រុមហ៊ុន។

៤- រចនាសម្ព័ន្ធបច្ចុប្បន្នដោយបញ្ចូលទាំងក្រុមហ៊ុនហូលឌីង ក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ បុគ្គលមានទំនាក់ទំនងពិសេស ញាតិសម្ព័ន្ធ និងសាខាទាំងអស់របស់ក្រុមហ៊ុន។

៥- របាយការណ៍សវនកម្ម និងលិខិតផ្សេងៗដែលទទួលបានពីសវនករឯករាជ្យ ប្រសិនបើមាន។

៦- កិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ ប្រសិនបើមាន។

៧- លិខិតបញ្ជាក់ពីក្រុមហ៊ុនពាក់ព័ន្ធដែលធានាកាតព្វកិច្ចបំណុលនៃក្រុមហ៊ុន និងបុគ្គលសម្ព័ន្ធទាំងអស់របស់ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធ ប្រសិនបើមាន។

៨- របាយការណ៍ ឬព័ត៌មានផ្សេងទៀតដែលកំណត់ដោយ **ន.ម.ក.**។

**ប្រការ៧ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវផ្តល់របាយការណ៍ជូន **ន.ម.ក.** តាមកាលបរិច្ឆេទដូចខាងក្រោម ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.ម.ក.**÷

១- របាយការណ៍ប្រចាំខែយ៉ាងយូរត្រឹមថ្ងៃទី១០ នៃខែបន្ទាប់។

២- របាយការណ៍ប្រចាំឆមាសយ៉ាងយូរ ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃបញ្ចប់ឆមាស។

៣- របាយការណ៍ប្រចាំឆ្នាំយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់។

ក្នុងករណីដែលកាលបរិច្ឆេទដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ត្រូវចំថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាកការងារដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវផ្តល់របាយការណ៍នៅថ្ងៃធ្វើការបន្ទាប់។

## ជំពូកទី ៣
## កាតព្វកិច្ចជូនដំណឹង

**ប្រការ៨ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវរក្សាមូលធនភាគហ៊ុនិកគ្រប់ពេលវេលាមិនឱ្យតិចជាងលក្ខខណ្ឌតម្រូវលើមូលធនអប្បបរមាដែលបានកំណត់ក្នុងប្រការ៤០ នៃប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ។

ក្នុងករណីមូលធនភាគហ៊ុនិកធ្លាក់ក្រោមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (Statement of Financial Position) ចុងក្រោយ និងវិធានការដំណោះស្រាយរបស់ក្រុមហ៊ុន។

**ប្រការ៩ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ក.** ក្នុងករណីមានការប្រែប្រួលនៃស្ថានភាពណាមួយដូចខាងក្រោម ដែលអាចជះឥទ្ធិពលជាសារវន្តដល់ក្រុមហ៊ុនក្នុងការប្រកបអាជីវកម្មផ្តល់ប្រឹក្សាហិរញ្ញវត្ថុ ឬដល់អតិថិជនរបស់ក្រុមហ៊ុន÷

១- ស្ថានភាពគ្រប់គ្រងរបស់ក្រុមហ៊ុន។

២- ទ្រព្យសកម្មរបស់ក្រុមហ៊ុន។

៣- ស្ថានភាពឥណទាន ឬបំណុលរបស់ក្រុមហ៊ុន។

៤- ស្ថានភាពវិនិយោគរបស់ក្រុមហ៊ុន។

៥- ការប្រែប្រួលផ្សេងទៀតដែលពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ការជូនដំណឹងត្រូវរួមបញ្ចូលទាំងការវាយតម្លៃអំពីឥទ្ធិពលនៃការប្រែប្រួលទាំងនោះលើក្រុមហ៊ុន និង អតិថិជនរបស់ក្រុមហ៊ុន ព្រមទាំងសកម្មភាព ឬវិធានការទាំងអស់ ដែលក្រុមហ៊ុនធ្វើឡើងដើម្បីគ្រប់គ្រងការប្រែប្រួលនោះ។

**ប្រការ១០ .-**

រាល់ការកែប្រែផែនការអាជីវកម្មរបស់ក្រុមហ៊ុន ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ភ.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃផ្លាស់ប្តូរ ដោយភ្ជាប់មកជាមួយនូវផែនការអាជីវកម្មថ្មី និងឯកសារបញ្ជាក់លើចំណុចដែលបានកែប្រែ។

**ប្រការ១១ .-**

ករណីក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុធ្វើការទាមទារសំណងក្នុងក្របខ័ណ្ឌកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ ឬធ្វើការផ្លាស់ប្តូរលក្ខខណ្ឌចម្បងនៃកិច្ចសន្យានោះ ដែលទាក់ទងនឹងអាជីវកម្មរបស់ក្រុមហ៊ុន ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ភ.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីមានការទាមទារសំណង ឬការផ្លាស់ប្តូរលក្ខខណ្ឌចម្បងនៃកិច្ចសន្យានោះ។

**ប្រការ១២ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ភ.** ប្រសិនបើក្រុមហ៊ុននោះ ក្រុមហ៊ុនហូលឌីង ក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ បុគ្គលមានទំនាក់ទំនងពិសេស ញាតិសម្ព័ន្ធ សាខា ការិយាល័យតំណាង ភាគហ៊ុនិក/សហកម្មសិទ្ធិករ ប្រធានភ្នាក់ងារផ្តល់ប្រឹក្សាហិរញ្ញវត្ថុ បុគ្គលិកជំនាញផ្នែកច្បាប់ ភ្នាក់ងារផ្តល់ប្រឹក្សាហិរញ្ញវត្ថុ ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននោះ ដែលនៅក្នុងអំឡុងពេលបំពេញមុខងារ ស្ថិតក្នុងស្ថានភាពដូចខាងក្រោម÷

១- រងការស៊ើបអង្កេត រងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានពិរុទ្ធភាព ឬត្រូវបានផ្តន្ទាទោសដោយសារការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅក្នុងយុត្តាធិការណាមួយ។

២- ជាប់បណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសកម្មភាពធុរកិច្ច ឬការអនុវត្តវិជ្ជាជីវៈក្នុងវិស័យមូលបត្រនៅក្នុងយុត្តាធិការណាមួយ។

៣- ទទួលរងពិន័យអន្តរការណ៍ ព្យួរឬដកហូតការចុះបញ្ជី ការអនុញ្ញាតឬអាជ្ញាបណ្ណ ឬត្រូវបានបដិសេធមិនឱ្យចុះបញ្ជី មិនផ្តល់ការអនុញ្ញាតឬមិនផ្តល់អាជ្ញាបណ្ណ ដោយនិយ័តករ ស្ថាប័នស្វ័យនិយ័តករ ឬអង្គភាពវិជ្ជាជីវៈក្នុងយុត្តាធិការណាមួយ។

**ប្រការ១៣ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលមានហេតុការណ៍ ឬមូលហេតុណាមួយដែលបណ្តាលឱ្យក្រុមហ៊ុនអាចឈានទៅរកការជម្រះបញ្ជី ការរំលាយក្រុមហ៊ុន ការផ្អាក ឬការឈប់ធ្វើអាជីវកម្មផ្តល់ប្រឹក្សាហិរញ្ញវត្ថុ។

**ប្រការ១៤ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ក.** អំពីអវត្តមានពីក្រុមហ៊ុនដោយគ្មានមូលហេតុ ការលាឈប់ ការឈប់សម្រាកលើសពីមួយខែ ការបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងារ របស់បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីអវត្តមានពីក្រុមហ៊ុនដោយគ្មានមូលហេតុរយៈពេល ៧ (ប្រាំពីរ) ថ្ងៃជាប់ៗគ្នា ឬទទួលបានការជូនដំណឹង, លិខិតលាឈប់ពីការងារឬលិខិតស្នើសុំឈប់សម្រាក ឬការសម្រេចបញ្ចប់តួនាទីឬការផ្លាស់ប្តូរមុខងាររបស់បុគ្គលនោះ។

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ក.** អំពីអវត្តមានពីក្រុមហ៊ុនដោយគ្មានមូលហេតុ ឬការឈប់សម្រាកលើសពីមួយខែ របស់ភ្នាក់ងារផ្តល់ប្រឹក្សាហិរញ្ញវត្ថុ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីអវត្តមានពីក្រុមហ៊ុនដោយគ្មានមូលហេតុរយៈពេល ៧ (ប្រាំពីរ) ថ្ងៃជាប់ៗគ្នា ឬទទួលបានលិខិតស្នើសុំឈប់សម្រាករបស់បុគ្គលនោះ។ ប្រសិនបើតំណែងសម្រាប់ភ្នាក់ងារផ្តល់ប្រឹក្សាហិរញ្ញវត្ថុនៅទំនេរ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជ្រើសរើសបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរមួយខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.ម.ក.**។ ក្នុងអំឡុងពេលដែលតំណែងសម្រាប់ភ្នាក់ងារផ្តល់ប្រឹក្សាហិរញ្ញវត្ថុនៅទំនេរ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវធានាឱ្យបាននូវនិរន្តរភាពនៃអាជីវកម្មផ្តល់ប្រឹក្សាហិរញ្ញវត្ថុ។

**ប្រការ១៥ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ក.** អំពីការឈប់សម្រាករបស់ក្រុមហ៊ុនមិនលើសពី ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ក្រៅពីថ្ងៃឈប់សម្រាកពីការងារដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ឱ្យបាន ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃឈប់សម្រាក។ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវធានាថាការឈប់សម្រាកនេះមិនប៉ះពាល់ដល់ផលប្រយោជន៍ជាសារវន្តរបស់អតិថិជន។

**ប្រការ១៦ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជូនដំណឹងជាបន្ទាន់មក **ន.ម.ក.** ក្នុងករណីមានចំណុចណាមួយដូចខាងក្រោម កើតឡើងចំពោះក្រុមហ៊ុនហូលឌីង ក្រុមហ៊ុនមេ បុគ្គលមានទំនាក់ទំនងពិសេស ឬបុត្រសម្ព័ន្ធ នៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជា÷

១- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការធ្វើអនុប្បទានអាជីវកម្មដោយផ្នែក ឬទាំងស្រុង។

២- ការហាមឃាត់ ឬការដាក់កម្រិតក្នុងការចេញមូលប្បទានប័ត្រ។

៣- ការចេញសេចក្តីសម្រេចរំលាយក្រុមហ៊ុន។

៤- ការចាប់ផ្តើមនៃនីតិវិធីណាមួយទាក់ទងនឹងនីតិវិធីនៃការក្ស័យធន។

៥- ករណីផ្សេងទៀតដែលតម្រូវដោយ **ន.ម.ក.**។

**ប្រការ១៧ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ក.** អំពីការដាក់ឱ្យប្រើប្រាស់ ឬផ្លាស់ប្តូរ គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម លេខទូរសព្ទ ឬអ៊ីមែលផ្ទាល់របស់ក្រុមហ៊ុន ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីដាក់ឱ្យប្រើប្រាស់ ឬផ្លាស់ប្តូរ។

## ជំពូកទី ៤
## កាតព្វកិច្ចស្នើសុំការអនុញ្ញាត

**ប្រការ១៨ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវស្នើសុំការអនុញ្ញាតពី **ន.ម.ក.** មុននឹង÷

១- រំលាយក្រុមហ៊ុនបញ្ចូលគ្នា ទិញក្រុមហ៊ុន ឬផ្ទេរប្រតិបត្តិការអាជីវកម្ម។

២- ផ្លាស់ប្តូរតំណាងនៃភាគហ៊ុនិកជានីតិបុគ្គល។

៣- ប្រើប្រាស់ ឬកែប្រែថ្លៃសេវា និងកម្រៃផ្សេងៗ។

៤- ផ្អាក ឬចាប់ផ្តើមអាជីវកម្មឡើងវិញ ឬឈប់ធ្វើអាជីវកម្មផ្តល់ប្រឹក្សាហិរញ្ញវត្ថុ។ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវផ្តល់ជូន **ន.ម.ក.** នូវនីតិវិធី និងឯកសារពាក់ព័ន្ធនឹងការឈប់ធ្វើអាជីវកម្មផ្តល់ប្រឹក្សាហិរញ្ញវត្ថុក្នុងរយៈពេលយ៉ាងតិច ៦(ប្រាំមួយ) ខែ មុនថ្ងៃឈប់ធ្វើអាជីវកម្ម។ នីតិវិធី និងរយៈពេលនៃការអនុវត្តនីតិវិធីឈប់ធ្វើអាជីវកម្មត្រូវទទួលការយល់ព្រមពី **ន.ម.ក.**។ ក្នុងករណីការអនុវត្តនីតិវិធីនៃការឈប់ធ្វើអាជីវកម្ម ប្រើប្រាស់ពេលលើសពីរយៈពេលទទួលបានការអនុញ្ញាត **ន.ម.ក.** មានសិទ្ធិកំណត់រយៈពេលបន្ថែម។

៥- បង្កើតបុត្រសម្ព័ន្ធ។ រាល់របាយការណ៍ដែលក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវផ្តល់ជូន **ន.ម.ក.** ត្រូវរួមបញ្ចូលព័ត៌មានពាក់ព័ន្ធនឹងបុត្រសម្ព័ន្ធនៅក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា។

៦- ផ្តល់ ឬបញ្ចប់ការផ្តល់មុខងារណាមួយរបស់ក្រុមហ៊ុនទៅឱ្យតតិយជន។

៧- ធ្វើអាជីវកម្មផ្សេងក្រៅពីអាជីវកម្មទីប្រឹក្សាហិរញ្ញវត្ថុដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ម.ក.**។

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវបំពេញតាមលក្ខខណ្ឌតម្រូវដែលកំណត់ដោយ **ន.ម.ក.** សម្រាប់ការស្នើសុំការអនុញ្ញាតដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការនេះ។

## ជំពូកទី ៥
## កម្រៃ និងសោហ៊ុយផ្សេងៗ

**ប្រការ១៩ ._**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតជូន **ន.ម.ក.** ទៅតាមករណីដូចខាងក្រោម÷

១- ចំពោះការស្នើសុំដូចមានចែងនៅក្នុងចំណុចទី១ ចំណុចទី៤ ឬចំណុចទី៥ នៃកថាខណ្ឌទី១ នៃប្រការ១៨ នៃប្រកាសនេះ

- ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ២.០០០.០០០ (ពីរលាន) រៀល។

២- ចំពោះការស្នើសុំដូចមានចែងនៅក្នុងចំណុចទី៦ ឬចំណុចទី៧ នៃកថាខណ្ឌទី១ នៃប្រការ១៨ នៃប្រកាសនេះ

- ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ១.០០០.០០០ (មួយលាន) រៀល។

៣- ចំពោះការស្នើសុំដូចមានចែងនៅក្នុងចំណុចទី២ នៃកថាខណ្ឌទី១ នៃប្រការ១៨ នៃប្រកាសនេះ

- ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០០.០០០ (មួយរយពាន់) រៀល។

៤- ចំពោះការស្នើសុំដូចមានចែងនៅក្នុងចំណុចទី៣ នៃកថាខណ្ឌទី១ នៃប្រការ១៨ នៃប្រកាសនេះ

- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០០.០០០ (មួយរយពាន់) រៀល។

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រការនេះ មិនត្រូវបានប្រគល់ជូនក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុវិញឡើយ ទោះបីជាការស្នើសុំត្រូវបានបដិសេធក៏ដោយ។

**ប្រការ២០ ._**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវបង់ប្រាក់ភាគទានជាប្រចាំខែចំនួន ០,៥ (សូន្យក្បៀសប្រាំ) ភាគរយនៃប្រាក់ចំណូលសរុបប្រចាំខែរបស់ក្រុមហ៊ុន ចូលក្នុងគណនីរបស់ **ន.ម.ក.** ក្នុងរយៈពេលយ៉ាងយូរត្រឹមថ្ងៃទី១០ នៃខែបន្ទាប់ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.ម.ក.** សម្រាប់ទ្រទ្រង់កិច្ចដំណើការរបស់ **ន.ម.ក.**។ **ន.ម.ក.** អាចធ្វើការផ្ទៀងផ្ទាត់ការបង់ប្រាក់ភាគទាននេះជាមួយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុន និងអាចតម្រូវឱ្យក្រុមហ៊ុនបង់ប្រាក់ភាគទានបន្ថែម ក្នុងករណីលទ្ធផលនៃការគណនាប្រាក់ភាគទានដែលក្រុមហ៊ុនត្រូវបង់ប្រចាំឆ្នាំ មានចំនួនច្រើនជាងផលបូកនៃប្រាក់ភាគទានដែលក្រុមហ៊ុនបានបង់រួចប្រចាំខែ។

**ប្រការ២១ .-**

រាល់កម្រៃ សោហ៊ុយផ្សេងៗ រួមទាំងប្រាក់ពិន័យត្រូវបង់ចូលក្នុងគណនីរបស់ **ន.ម.ភ.**។

## ជំពូកទី ៦
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ២២ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវរៀបចំរាល់របាយការណ៍ និងព័ត៌មាន អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដោយប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ ដើម្បីធានាឱ្យបាននូវភាពសុក្រឹត ច្បាស់លាស់ និងពេញលេញ។ ប្រសិនបើកំហុសឆ្គង ឬការខ្វះខាតណាមួយត្រូវបានរកឃើញ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ភ.** និងត្រូវផ្តល់សារជាថ្មីនូវរបាយការណ៍ និងព័ត៌មានដែលកែតម្រូវរួច។

**ប្រការ២៣ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងៗតាមការតម្រូវរបស់ **ន.ម.ភ.** ដើម្បីកំណត់ពីភាពត្រឹមត្រូវរបស់ក្រុមហ៊ុន ក្នុងការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិ ឬសេចក្តីណែនាំរបស់ **ន.ម.ភ.**។

**ប្រការ២៤ .-**

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុត្រូវរៀបចំរបាយការណ៍ និងផ្តល់ព័ត៌មានអនុលោមតាមប្រកាសនេះ ក្នុងទម្រង់ដែលកំណត់ដោយ **ន.ម.ភ.**។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**ប្រការ២៥ .-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុដែលប្រព្រឹត្តល្មើស ឬផ្តល់ព័ត៌មានខុសដោយចេតនា ឬដោយធ្វេសប្រហែសធ្ងន់ធ្ងរនឹងប្រការ៤, ប្រការ៥, ប្រការ៦, ប្រការ៨, ប្រការ៩, ប្រការ១០, ប្រការ១១, ប្រការ១២, ប្រការ១៣, ប្រការ១៤, ប្រការ១៥, ប្រការ១៦, ប្រការ១៧, ប្រការ១៨, ប្រការ២២, ប្រការ២៣, ប្រការ២៤ ឬមិនគោរពតាមការណែនាំ ការកំណត់ ឬការតម្រូវរបស់ **ន.ម.ភ.** ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងនៅក្នុងប្រការ២៦ នៃប្រកាសនេះ និង/ឬទទួលពិន័យអន្តរការណ៍ពី **ន.ម.ភ.** ជាប្រាក់មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល។

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុដែលយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ ការជូនដំណឹង ឬការបង់ប្រាក់ភាគទានតាមរយៈពេល ឬកាលបរិច្ឆេទដូចមានកំណត់នៅក្នុងប្រការ៧ និងប្រការ២០ នៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងប្រការ២៦ នៃប្រកាសនេះ និង/ឬទទួលពិន័យអន្តរការណ៍ពី **ន.ម.ភ.** ជាប្រាក់ចំនួន ១.០០០.០០០(មួយលាន) រៀល ក្នុងមួយថ្ងៃ ចំពោះការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ ការជូនដំណឹង ឬការបង់ប្រាក់ភាគទាន ជូន **ន.ម.ភ.**។

ក្នុងករណីមិនរាងចាល បុគ្គលប្រព្រឹត្តល្មើសត្រូវទទួលពិន័យអន្តរការណ៍ទ្វេដង។

ក្នុងករណីការប្រព្រឹត្តល្មើសបានបង្កឱ្យមានព្យសនកម្ម បុគ្គលប្រព្រឹត្តល្មើសត្រូវទទួលរងពិន័យអន្តរការណ៍ពី **ន.ម.ភ.** និង/ឬជួសជុលសំណងព្យសនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មុននឹងចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី១, កថាខណ្ឌទី២, កថាខណ្ឌទី៣ ឬកថាខណ្ឌទី៤ នៃប្រការនេះ **ន.ម.ភ.** ត្រូវផ្តល់ឱកាសឱ្យបុគ្គលប្រព្រឹត្តល្មើសធ្វើការស្រាយបំភ្លឺជាមុនសិន។

**ប្រការ២៦ .-**

ទណ្ឌកម្មរដ្ឋបាលមានដូចខាងក្រោម÷

១- ការព្រមាន ឬដាស់តឿន។

២- ការដឹកនាំកែតម្រង់។

៣- ការព្យួរ ឬបណ្តេញបុគ្គលិកជាន់ខ្ពស់ចេញពីមុខតំណែង។

៤- ការដាក់កម្រិតលើអាជ្ញាបណ្ណ/ការអនុញ្ញាត។

៥- ការព្យួរអាជ្ញាបណ្ណ/ការអនុញ្ញាត។

៦- ការដកហូតអាជ្ញាបណ្ណ/ការអនុញ្ញាត។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**ប្រការ២៧ .-**

**ន.ម.ភ.** អាចចេញគោលការណ៍ណែនាំអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្ត។

**ប្រការ២៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៩ .-**

អគ្គនាយកនៃ **ន.ម.ភ.** ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត គ្រប់ប្រធាននាយកដ្ឋានស្ថិតក្រោមចំណុះ **ន.ម.ភ.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៨ រោច ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តមនិងលោកជំទាវអនុប្រធាន និងសមាជិកក្រុមប្រឹក្សា-អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២៩
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ